**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(១៨)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 21-Nov-2012, 14:51
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ**/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់លោក អៀង សារី ទៅនឹងបណ្ដឹងសាទុក្ខបន្ទាន់របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីវិសាលភាពនៃការជំនុំជម្រះក្ដីនៅក្នុងសំណុំរឿង ០០២/០១**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**<u>អង្គជំនុំជម្រះតុលាការកំពូល៖</u>**

**ចៅក្រម** គង់ ស្រ៊ឹម

**ចៅក្រម** សោម សិរីវឌ្ឍ

**ចៅក្រម** Agnieszka KLONOWIECKA-MILART

**ចៅក្រម** ម៉ុង មុន្នីចរិយា

**ចៅក្រម** Chandra Nihal JAYASINGHE

**ចៅក្រម** យ៉ា ណារិន

**ចៅក្រម** Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះ សូមធ្វើការឆ្លើយតប ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុង សំណុំរឿង ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II) ("បណ្តឹងសាទុក្ខ")[1]។ បណ្តឹង សាទុក្ខនេះ មិនអាចទទួលយកបានទេនៅដំណាក់កាលនៃដំណើរការនីតិវិធីនេះ។ ការដាក់បណ្តឹងសាទុក្ខ ត្រូវបានរារាំងដោយពេលវេលា។ បើទោះបីជារយៈពេលក្នុងការដាក់បណ្តឹងសាទុក្ខក្តីមិនទាន់កន្លងផុតក្តី ក៏ បណ្តឹងសាទុក្ខភ្លាមៗទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្តី មិនត្រូវបានអនុញ្ញាតទេ ផ្អែកតាមវិធាន ផ្ទៃក្នុងរបស់ អ.វ.ត.ក។ ផ្អែកតាមមូលដ្ឋាននេះ និងដើម្បីជាផលប្រយោជន៍នៃសេដ្ឋកិច្ចតុលាការ មេធាវី ការពារក្តី នឹងកំហិតខ្លឹមសារក្នុងចម្លើយតបនេះ ត្រឹមតែបញ្ហានៃយុត្តាធិការ និងភាពអាចទទួលយកបាន តែប៉ុណ្ណោះ[2]។ សាវតារពាក់ព័ន្ធ ត្រូវបានលើកឡើងដូចខាងក្រោម សម្រាប់គោលបំណងបរិបទ ជាពិសេស បរិបទទាក់ទងនឹងបញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើយុត្តាធិការរបស់ខ្លួន ដែរ ឬយ៉ាងណា ក្នុងការខកខានរបស់ខ្លួនមិនបានពិចារណាឲ្យបានគ្រប់គ្រាន់ចំពោះទឡ្ហីករណ៍របស់ ក.ស.ព ទាក់ទងនឹងវិសាលភាពនៃការជំនុំជម្រះក្តី។

## I. **សាវតារ**

1. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ មុនពេលចាប់ផ្តើមការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង បានបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ "ទៅជាផ្នែកតូចៗ ដោយដាក់បញ្ចូល ការចោទប្រកាន់លើអង្គហេតុ និងបញ្ហាអង្គច្បាប់ជាក់លាក់ដែលពាក់ព័ន្ធ"[3]។ អង្គជំនុំជម្រះសាលា ដំបូង "បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដើម្បីជាប្រយោជន៍នៃយុត្តិធម៌"[4] ដោយយល់ឃើញ ថា ការបំបែកសំណុំរឿងនឹង "ការពារបាននូវផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះក្នុងការ

[1] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេច ស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង ០០២/០១ មានឧបសម្ព័ន្ធ (I) និងឧបសម្ព័ន្ធសម្ងាត់ (II) ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E163/5/1/1។

[2] នេះគឺជាវិធីសាស្ត្រដែលជាទូទៅប្រើប្រាស់ដោយ ក.ស.ព។ *សូមមើល ឧទា.* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឲ្យជនជាប់ចោទត្រូវមាន វត្តមានដើម្បីស្តាប់ការចោទប្រកាន់ និងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារ E130/4/2។

[3] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124 កថាខណ្ឌ ២។

[4] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៥។

ទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ព្រមទាំងការពារបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័សរបស់ជនជាប់ចោទទាំងអស់ នៅក្នុងសំណុំរឿង ០០២ ទៀតផង"[5]។

2. នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ក.ស.ព បានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា សហព្រះរាជអាជ្ញាស្នើសុំឱ្យពិចារណាឡើងវិញ លើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី[6]។ នៅក្នុងសេចក្តីជូនដំណឹងនេះ ក.ស.ព បានលើកឡើងថា សហព្រះរាជអាជ្ញា "សូមគាំទ្រទាំងស្រុងនូវការចាំបាច់ក្នុងការបំបែកសំណុំរឿង ០០២ និងគោរពតាមសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ និងបើមិនដូច្នោះទេ គឺដើម្បីធ្វើការគ្រប់គ្រងលើការបែងចែកពេលវេលា និងធនធាននៅពេលសវនាការ"[7]។ ក.ស.ព បានកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញានឹង "ត្រៀមរៀបចំនូវអនុសាសន៍មួយចំនួនដែលផ្តោតចំៗដើម្បីដាក់បញ្ចូលនូវកម្រងជ្រើសរើសតូចមួយ នៃអំពើឧក្រិដ្ឋដែលជាតំណាងឱ្យអំពើឧក្រិដ្ឋដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ"[8]។

3. នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ មេធាវីការពារក្តី បានឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងរបស់ ក.ស.ព និងបានស្នើសុំឱ្យមានសវនាការសួរដេញដោលផ្ទាល់មាត់ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង សម្រេចតាមសំណើរបស់ ក.ស.ព សុំឱ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី[9]។

4. នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ ក.ស.ព បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យពិចារណាឡើងវិញចំពោះដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន និងសុំឱ្យបញ្ចូលទីតាំងឧក្រិដ្ឋកម្ម

[5] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៨។

[6] សេចក្តីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញលើពាក្យ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124/1។

[7] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៤។

[8] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៥។

[9] ការគាំទ្រដោយមានលក្ខខណ្ឌរបស់លោក អៀង សារី ចំពោះសេចក្តីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញាសុំពិចារណាឡើងវិញនូវលក្ខខណ្ឌនៃ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/3។

បន្ថែមមួយចំនួននៅក្នុងសំណុំរឿង០០២/០១ ឬជម្រើសផ្សេងមួយទៀត ផ្តល់ឱកាសឲ្យគ្រប់ភាគីទាំងអស់ចូលរួមស្តាប់សវនាការ ស្តីពីខ្លឹមសារនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីតាមរយៈការសួរដេញដោលផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ[10]។ ក.ស.ព បានលើកឡើងនូវសំណើនេះដោយកត់សម្គាល់ឃើញថា សំណុំរឿង ០០២/០១ "នឹងទំនងជាការជំនុំជម្រះក្តីតែមួយគត់ចំពោះជនជាប់ចោទ" និង "មិនជាតំណាងនៃការប្រព្រឹត្តបទឧក្រិដ្ឋដែលចោទប្រកាន់របស់ពួកគេនោះទេ"[11]។ សហព្រះរាជអាជ្ញា បានលើកទឡ្ហីករណ៍ថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី "នឹងកាត់បន្ថយកេរតំណែល"របស់អ.វ.ត.ក និង "មិនបានធានានូវផលប្រយោជន៍របស់ជនរងគ្រោះជាមូលដ្ឋាននោះទេ"[12]។

5. នៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ មេធាវីការពារក្តី បានឆ្លើយតបទៅនឹងសំណើរបស់ក.ស.ព ស្នើសុំឲ្យមានការពិចារណាឡើងវិញ។ ដោយប្រកាន់លើជំហរអព្យាក្រឹត្យត្រង់ចំណុចថាតើមាន ឬមិនមានមូលដ្ឋានសម្រាប់ការពិចារណាឡើងវិញ មេធាវីការពារក្តីបានលើកឡើងថា៖ **ក.** ការពិចារណាឡើងវិញ អាចអនុញ្ញាតឲ្យបាន។ **ខ.** ការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវតែស្របតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង។ **គ.** គោលការណ៍ណែនាំស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីមិនអាចយកពីតុលាការ ICTY បានទេ ដោយសារតែភាពខុសគ្នានៅក្នុងប្រព័ន្ធគតិយុត្តិជាមូលដ្ឋានរបស់ខ្លួន (ប្រព័ន្ធសួរដេញដោលភាគី ដែលខុសគ្នានឹងប្រព័ន្ធច្បាប់ស៊ីវិល) និងវិធានជាធរមាន។ **ឃ.** ការចោទសួររបស់ ក.ស.ព ដែលថា តើនឹងមានការជំនុំជម្រះនាពេលអនាគត ឬយ៉ាងណានោះគឺជាការពុំត្រឹមត្រូវទេ។ **ង.** ក.ស.ព ពុំបានបង្ហាញថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីពុំមែនធ្វើឡើងដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ឡើយ និង **ច.** សំណើសុំផ្សេងទៀតក្នុងការបំបែកកិច្ចដំណើរការនីតិវិធី ដែលស្នើសុំដោយ ក.ស.ព នឹងពុំធ្វើឲ្យការជំនុំជម្រះប្រព្រឹត្តទៅបាន

---

[10] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញចំពោះ "ដីកាបំបែកដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/2។

[11] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣។ *សូមមើលផងដែរ* កថាខណ្ឌ ២៤៖ "ដីកាបំបែកដំណើរការនីតិវិធី អាចប្រមើលមើលឃើញជនជាប់ចោទអាចនឹងទទួលការជំនុំជម្រះលើសពីរមួយដង។ ករណីនេះទំនងជាមិនអាចទៅរួចនោះទេ"។

[12] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣។

ឆាប់រហ័សនោះទេ[13]។

6. នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសំណើរបស់ក.ស.ព សុំឱ្យពិចារណាឡើងវិញ និងស្នើសុំឱ្យមានសវនាការជាសាធារណៈ[14]។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់អំពីគោលបំណងរបស់ខ្លួន ក្នុងការបំបែកសំណុំរឿងតាមរបៀបដែលខ្លួនបានធ្វើ[15] និងបានរៀបរាប់បន្ថែមថា "ដោយសារតែការចោទប្រកាន់ ឬបទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានទំនាក់ទំនងបន្តបន្ទាប់គ្នានៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនោះ ហេតុដូច្នេះការជំនុំជម្រះដំណាក់កាលដំបូង មិនចាំបាច់គ្របដណ្តប់លើបទចោទទាំងមូល នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ"[16] ។ <u>ក.ស.ព មិនបានដាក់បណ្តឹងសាទុក្ខនោះទេ</u>។

7. នៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ក.ស.ព បានស្នើសុំឱ្យធ្វើការបញ្ជាក់អំពីវិសាលភាពនៃសំណុំរឿង ០០២/០១[17] និងបានស្នើសុំអង្គជំនុំជម្រះសាលាដំបូង *ក្នុងចំណោមសំណើសុំផ្សេងៗ* ដើម្បី "ធ្វើការបញ្ជាក់ថា កថាខណ្ឌទី៧ នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី តាមវិធីណាមួយក៏ដោយ មិនកម្រិតឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានយោងនៅក្នុងកថាខណ្ឌទី៦ ក្នុងការដាក់បញ្ចូលនូវការចោទប្រកាន់ ឬបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាការបន្ថែមទៅនឹងការចោទប្រកាន់ ឬបទចោទដែលបានកំណត់អត្តសញ្ញាណរួចហើយ នៅក្នុងកថាខណ្ឌទី៥ នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសវនាការដំបូងនោះឡើយ"[18]។

---

[13] ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញទៅលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារE124/6។

[14] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/7។

[15] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១០។

[16] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៩។

[17] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E124/9។

[18] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៣។

8. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្ដីបានឆ្លើយតបទៅនឹងសំណើរបស់ក.ស.ព សុំឲ្យធ្វើការបញ្ជាក់ ដោយអះអាងថា សំណើសុំនេះ គឺគ្រាន់តែជាវិធីមួយដើម្បីស្នើសុំឲ្យពិចារណាឡើងវិញនូវដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីជាលើកទីពីរប៉ុណ្ណោះ[19]។

9. នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈមួយដោយបានជូនដំណឹងដល់ភាគីនានាអំពីសេចក្ដីសម្រេចរបស់ខ្លួនលើសំណើសុំជាច្រើន ដោយរួមបញ្ចូលទាំងសំណើរបស់ ក.ស.ព ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ សុំឲ្យធ្វើការបញ្ជាក់។ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា "អង្គជំនុំជម្រះ ... សូមបញ្ជាក់ថា វិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ដែលជាមូលដ្ឋាននៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិរៀបចំសវនាការ ដោយភាគីពុំមានសិទ្ធិប្ដឹងសាទុក្ខឡើយ"[20]។ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងបន្ថែមថា "សំណើទាំងឡាយ ដែលស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ទោះបីក្នុងប្រភេទជាសំណើសុំជា"ការបញ្ជាក់បំភ្លឺ" ជាចម្លើយតប ឬផ្សេងពីនេះក៏ដោយ ហើយការធ្វើបែបនេះ អាចត្រូវបានចាត់ទុកដោយអង្គជំនុំជម្រះថាជាការព្យាយាមអូសបន្លាយកិច្ចដំណើរការនីតិវិធី"[21]។ ក.ស.ព មិនបានដាក់បណ្ដឹងសាទុក្ខនោះទេ។

10. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ក.ស.ព បានព្យាយាមម្ដងទៀតដើម្បីពង្រីកវិសាលភាពនៃការជំនុំជម្រះ ដោយបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឲ្យរួមបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួនបីទៅក្នុងសំណុំរឿង ០០២/០១[22] *ក្នុងចំណោមទឡ្ហីករណ៍ផ្សេងៗ* បានលើកទឡ្ហីករណ៍ថាការពង្រីកវិសាលភាពនេះ គឺចាំបាច់សម្រាប់ "តំណាងសមហេតុផលនូវវិសាលភាពអង្គហេតុ

---

[19] ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E124/9/1 សេចក្ដីផ្ដើម។

[20] សេចក្ដីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើ ដែលនៅសេសសល់មុនសវនាការ (ឯកសារ E20, E132, E134, E135, E124/8, E124/9, E124/10, E136 និង E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E145 ទំព័រ១ (គូសបញ្ជាក់បន្ថែម)។

[21] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ២។

[22] សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ឯកសារ E163។

នៅក្នុងសវនាការ"[23]។

11. នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្ដី បានឆ្លើយតបទៅនឹងសំណើរបស់ ក.ស.ព សុំឱ្យដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មចំនួនបីថែមទៀត ដោយកត់សម្គាល់ឃើញថា សំណើសុំនេះ "គឺជាការប៉ុនប៉ងជាថ្មីមួយទៀតដោយ ក.ស.ព ដើម្បីស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យពិចារណាសាឡើងវិញនូវដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន" និងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលសំណើសុំនេះ[24]។

12. នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដែលលើកឡើងអំពីក្រុមសាក្សីបន្តបន្ទាប់ ដែលត្រូវស្ដាប់ចម្លើយនៅក្នុងសំណុំរឿង ០០២/០១។ នៅក្នុងអនុស្សរណៈនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា៖

> អង្គជំនុំជម្រះបានទទួលនូវសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើសុំឱ្យបញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មមួយចំនួនទៅក្នុងវិសាលភាពនៃអង្គហេតុ ដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)។ មេធាវីការពារក្ដីជនជាប់ចោទ អៀង សារី និង ខៀវ សំផន បានឆ្លើយតបជាបន្តបន្ទាប់ទៅនឹងសំណើសុំខាងលើរបស់សហព្រះរាជអាជ្ញា (ឯកសារ E163/1 និង E163/2)។ ដូចដែលអង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី និងនៅក្នុងសេចក្ដីសម្រេចពាក់ព័ន្ធនានាកាលពីពេលមុននោះ អង្គជំនុំជម្រះអាចពន្លាតវិសាលភាពអង្គហេតុសម្រាប់សវនាការសំណុំរឿង០០២/០១ ទៅតាមគំនិតផ្ដួចផ្ដើម និងឆន្ទានុសិទ្ធិរបស់ខ្លួន។ ប្រសិនបើអង្គជំនុំជម្រះសម្រេចពន្លាតវិសាលភាពនៃសំណុំរឿង ០០២/០១ នោះ អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគីក្នុងពេលវេលាមួយសមស្របជាមុន។ នេះគឺជាចម្លើយរបស់អង្គជំនុំជម្រះទៅនឹងសំណើសុំនៅក្នុងឯកសារ E163[25]។

<u>ក.ស.ព មិនបានដាក់បណ្ដឹងសាទុក្ខនោះទេ។</u>

---

[23] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ៥។

[24] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើរឿងក្ដី ០០២/០១ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E163/1។

[25] សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E172 ទំព័រ ៤ (គូសបញ្ជាក់បន្ថែម)។

13. នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ[26]។ អនុស្សរណៈនេះ បានលើកឡើងថា "អង្គជំនុំជម្រះមានចេតនាបញ្ចប់សវនាការដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ ក្នុងឆ្នាំ ២០១៣ និងចាប់ផ្តើមសំណុំរឿង ០០២/០២ ភ្លាមៗ ក្រោយការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១ នោះ ..."[27]។ អនុស្សរណៈបានបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង *អាច*មានបំណងពិចារណាលើការពង្រីកវិសាលភាពសមហេតុផល នៃសំណុំរឿង ០០២/០១ ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់ជាមួយនេះ និងបានអញ្ជើញឲ្យភាគីនានាដាក់សារណាផ្តោតចំៗលើបញ្ហានេះនៅពេលកិច្ចប្រជុំរៀបចំសវនាការ[28]។ អង្គជំនុំជម្រះសាលាដំបូង បានណែនាំឲ្យភាគីនានាលើកឡើងអំពីបញ្ហាផ្សេងៗសម្រាប់កិច្ចពិភាក្សា នៅក្នុងកិច្ចប្រជុំរៀបចំសវនាការ "*ជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់*" និង "*មិនឲ្យហួសពីថ្ងៃ សុក្រ ទី ១០ ខែ សីហា ឆ្នាំ ២០១២ ឡើយ*"[29]។

14. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ ក.ស.ព បានដាក់សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ (ដោយមានឧបសម្ព័ន្ធសម្ងាត់ ក)[30] ដែលការដាក់សេចក្តីជូនដំណឹងនេះហួសរយៈពេលកំណត់របស់អង្គជំនុំជម្រះសាលាដំបូងរយៈពេលប្រាំថ្ងៃ។ នៅក្នុងសេចក្តីជូនដំណឹងនេះ ក.ស.ព បានស្នើសុំឲ្យស្តាប់ចម្លើយសាក្សីបន្ថែមមួយចំនួន និងស្នើសុំឲ្យដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួនបី៖ មន្ទីរស-២១, ស្រុក១២ និងទួលពោធិ៍ជ្រៃ។ ក.ស.ព ក៏បានកំណត់អំពី

---

26 ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E218។

27 *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១។

28 *ដូចជើងទំព័រខាងលើ* កថាខណ្ឌ១៣-១៥។

29 *ដូចជើងទំព័រខាងលើ* ទំព័រ ១ (គូសបញ្ជាក់បន្ថែម)។

30 សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ (ដោយមានឧបសម្ព័ន្ធសម្ងាត់ ក) ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E218/2។

កាលបរិច្ឆេទសវនាការដែលស្នើសុំ ដោយបានរួមបញ្ចូលទីតាំងទាំងនេះនៅក្នុងសំណុំរឿង ០០២/០១។

15. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ មេធាវីការពារក្តី បានដាក់ញត្តិសុំលុបចោលសេចក្តីជូនដំណឹងលើបញ្ហាសំខាន់ៗរបស់សហព្រះរាជអាជ្ញា ដែលត្រូវពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការ[31] ពីព្រោះ ក.ស.ព មិនបានគោរពយ៉ាងច្បាស់ចំពោះសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការលើកយកបញ្ហាណាមួយសម្រាប់ធ្វើការពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការ *"ជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់"* និង *"មិនឲ្យហួសពីថ្ងៃ សុក្រ ទី ១០ ខែ សីហា ឆ្នាំ ២០១២"*[32]។ ក.ស.ព ដែលបានដាក់សេចក្តីជូនដំណឹងចំនួន១៥ទំព័រ មុនតែមួយថ្ងៃនៃកិច្ចប្រជុំរៀបចំសវនាការ មិនបានស្នើសុំការដាក់សេចក្តីជូនដំណឹង និងមិនបានផ្តល់យុត្តិកម្មណាមួយចំពោះការដាក់សារណារបស់ខ្លួនដែលមិនទាន់ពេលវេលា ឬមិនបានផ្តល់យុត្តិកម្មចំពោះការដាក់ឯកសារជាផ្លូវការរបស់ខ្លួន ដែលផ្ទុយនឹងការដាក់សារណាជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដូចដែលបានណែនាំនោះទេ។

16. នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការពេញមួយថ្ងៃដើម្បីពិភាក្សាលើវិសាលភាពនៃការជំនុំជម្រះ *ក្នុងចំណោមកិច្ចពិភាក្សាលើបញ្ហាផ្សេងៗទៀត*។ ក្នុងអំឡុងពេលកិច្ចប្រជុំនេះ មានតែសហព្រះរាជអាជ្ញាអន្តរជាតិមួយរូប Andrew Cayley ដែលបានបង្ហាញខ្លួននៅក្នុងតុលាការដើម្បីលើកឡើងអំពីសារណារបស់ ក.ស.ព[33] ទាក់ទិននឹងការពង្រីក

---

[31] ញត្តិរបស់ អៀង សារី សុំលុបចោលសេចក្តីជូនដំណឹងនៃជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗដែលត្រូវពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ១៧ ខែ សីហា និងឧបសម្ព័ន្ធរបស់ខ្លួន ឬជាជម្រើសមួយផ្សេងទៀត ស្នើសុំឆ្លើយតប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E218/3។

[32] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ" ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E218 ទំព័រ១ (គូសបញ្ជាក់បន្ថែម)។

[33] វាមានការគូសបញ្ជាក់ថា នៅពេលតែងតាំងគាត់ជាសហព្រះរាជអាជ្ញាអន្តរជាតិរបស់អ.វ.ត.ក លោក Cayley បានប្រកាសជាសាធារណៈថា *"ខ្ញុំនឹងដឹកនាំចាប់ពីពេលដំបូងមក។ ខ្ញុំនឹងចូលរួមនៅក្នុងបន្ទប់សវនាការ"*។ (*សូមមើល* Douglas Gillison, ព្រះរាជអាជ្ញាថ្មីរបស់តុលាការខ្មែរក្រហម សន្យាចូលរួមសវនាការគ្រប់ពេលវេលា ចុះក្នុងកាសែតខេមបូឌា ដេលី ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១០ គូសបញ្ជាក់បន្ថែម)។ ទោះបីជាយ៉ាងណាក៏ដោយ លោក Cayley ដែលកម្រឃើញចូលរួមនៅក្នុងតុលាការៈ បាននិយាយនៅក្នុងតុលាការក្នុងសំណុំរឿង០០២ តែប្រហែលជា៧ដងប៉ុណ្ណោះ។ ហេតុដូច្នេះ គេអាចសន្និដ្ឋានបានថា ភាពសំខាន់នៃការចូលរួមសវនាការដែលខុសពីធម្មតារបស់លោក Cayley មិនបានធ្វើឲ្យអង្គជំនុំជម្រះពិបាកយល់នោះទេ។ ការចូលរួមតែ

វិសាលភាពលើសំណុំរឿង ០០២/០១ ដោយបង្ហាញនូវទស្សនៈថា បញ្ហានេះ គឺជា “បញ្ហាសំខាន់”[34]។

17. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានផ្ញើអ៊ីមែល ទៅភាគីនានាដើម្បីធ្វើការកត់សម្គាល់ថា នៅកិច្ចប្រជុំរៀបចំសវនាការថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២៖ “ដំណាក់កាលចុងក្រោយនៃកិច្ចពិភាក្សាលើសំណើរបស់ ក.ស.ព សុំឲ្យពង្រីកវិសាលភាពនៃការជំនុំជម្រះក្តី ត្រូវតែបញ្ចប់ឲ្យបានឆាប់រហ័ស។ ដើម្បីកុំឲ្យប៉ះពាល់ដល់ភាគីណាមួយ ដែលកើតចេញមកពីបញ្ហានេះ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា ភាគីនានានឹងអាចដាក់ជូនអង្គជំនុំជម្រះជាលាយលក្ខណ៍អក្សរ ស្តីពីបញ្ហាដែលនៅសេសសល់បន្តិចបន្តួចទៅលើប្រធានបទនេះ ដែលមិនអាចធ្វើការពិភាក្សាបាននៅពេលកិច្ចប្រជុំរៀបចំសវនាការដោយសារតែពេលវេលាមានកំណត់”[35]។

18. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់ចម្លើយតបទៅនឹងសំណើសុំកោះហៅសាក្សី និងអ្នកជំនាញបន្ថែមដែល ក.ស.ព បានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងរបស់ខ្លួនអំពីបញ្ហាសំខាន់ៗ ដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការ[36]។ មេធាវីការពារក្តីបានលើកឡើងថា ក.ស.ព បានខកខានពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការបង្ហាញថាមាន “សំអាងហេតុសមស្រប” សម្រាប់សាក្សីថ្មីៗដែលទើបស្នើសុំឲ្យមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ ហើយថា សំណើនេះគឺជាការប៉ុនប៉ងគេចចេញពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ហើយនឹងធ្វើឲ្យប៉ះពាល់ដល់គោលបំណងនៃការបំបែកសំណុំរឿង ដើម្បីមានការជំនុំជម្រះប្រកបដោយប្រសិទ្ធផល និងខ្លី និងដើម្បីទទួលបានសាលក្រមនៅពេលដែលជនជាប់ចោទទាំងអស់នៅមានជីវិតនៅឡើយ។

19. នៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយជូនដំណឹង ដល់ភាគីនានាអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ ក.ស.ព សុំដាក់ បញ្ចូល

---

បន្តិចបន្តួចរបស់តួអង្គសំខាន់ ដូចជា លោក Cayley នឹងប្រាកដជាធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់នូវទម្ងន់បន្ថែមទៅនឹងជំហររបស់ក.ស.ព មុនពេលអង្គជំនុំជម្រះចេញសេចក្តីសម្រេចរបស់ខ្លួន។

[34] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារE1/114.1 ទំព័រ៩៥-១០២ ដកស្រង់ទំព័រ៩៥។

[35] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើទៅគ្រប់ភាគីទាំងអស់ មានចំណងជើងថា ៖ “ការបន្តតាមដានពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃសុក្រសប្តាហ៍មុន” ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២។

[36] ចម្លើយតបរបស់លោក អៀង សារី អនុលោមតាមវិធាន៨៧(៤) ទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា សុំកោះហៅសាក្សី TCW-505, TCW-754, TCW-100, TCE-33, TCW-720, TCW-781 និងសាក្សី TCW-164 ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E218/3/1។

ទីកន្លែងឧក្រិដ្ឋកម្មបន្ថែម (“សេចក្តីសម្រេចដែលត្រូវបានជំទាស់”)[37]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដាក់បញ្ចូលទួលពោធិ៍ជ្រៃទៅក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែមិនដាក់បញ្ចូលមន្ទីរ ស២១ ឬ ស្រុក ១២ ឡើយ ដោយពិចារណាថា ការធ្វើដូច្នេះនឹងមិនមែនជា “ការអនុវត្តដោយប្រុងប្រយ័ត្ន នៃឆន្ទានុសិទ្ធិក្នុងការរៀបចំសវនាការរបស់អង្គជំនុំជម្រះឡើយ”[38]។

20. នៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ក.ស.ព បានដាក់បណ្តឹងសាទុក្ខរបស់ខ្លួន។ ចំពោះភាពអាចទទួលយកបាននោះ ក.ស.ព បានអះអាងថា បណ្តឹងសាទុក្ខនេះគឺអាចទទួលយកបានជាបណ្តឹងសាទុក្ខភ្លាមៗ អនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង ហើយថា បណ្តឹងសាទុក្ខនេះបានដាក់នៅក្នុងពេលកំណត់ដែលអាចដាក់បាន[39]។

## II. ចម្លើយតប

### ក. បណ្តឹងសាទុក្ខត្រូវបានរារាំងដោយពេលវេលា និងគួរតែបដិសេធចោល

21. បណ្តឹងសាទុក្ខគឺគ្រាន់តែជាការប៉ុនប៉ង ដែលមានលក្ខណៈលាក់លៀមមិនបង្ហាញឲ្យឃើញច្បាស់ និងយឺតពេលទៅហើយក្នុងការប្តឹងសាទុក្ខចំពោះវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលមានកំណត់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ បណ្តឹងសាទុក្ខនេះធ្វើឡើងមិនត្រឹមត្រូវតាមពេលវេលាកំណត់ឡើយ។

22. វិធាន ១០៧(១) ចែងថា “ក្នុងករណីដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បើកឲ្យមានបណ្តឹងសាទុក្ខភ្លាម ដូចមានចែងក្នុងវិធាន ១០៤ (៤) វាក្យខណ្ឌ (ក) (ឃ) និង (ង) បណ្តឹងសាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ចាប់ពីថ្ងៃប្រកាសសេចក្តីសម្រេច ឬ ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនោះ”[40]។ ក.ស.ព ពុំបានស្វះស្វែងប្តឹងសាទុក្ខឡើយ នៅពេលដែល ក.ស.ព ដឹងច្បាស់ថា ការបែងចែកការជំនុំជម្រះក្តីដំបូងនៃសំណុំរឿង ០០២ នឹងកំណត់ត្រឹមតែវិសាលភាព (និងរារាំងចំពោះ

---

[37] សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E163/5។

[38] ដូចយោងខាងលើ កថាខណ្ឌ ២។

[39] បណ្តឹងសាទុក្ខ កថាខណ្ឌ ១០-២០។

[40] សេចក្តីបញ្ជាក់បន្ថែម។

ការធ្វើស្រេចតែចិត្តក្នុងការពង្រីកប្រភេទដែលមិនមានសារៈសំខាន់ ដោយអង្គជំនុំជម្រះសាលាដំបូង) ដែលបានកំណត់នៅក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។

23. រយៈពេលជាងមួយឆ្នាំកន្លងមកហើយ និងនៅមុនពេលការចាប់ផ្តើមការជំនុំជម្រះក្តី អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១[41]។ ក.ស.ព ជាយុទ្ធសាស្ត្របានសម្រេចមិន (ឬខកខានមិន) ប្តឹងសាទុក្ខទៅលើដីកានោះឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ក.ស.ព បានស្នើឲ្យពិចារណាទៅលើដីកានោះ[42]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះជាងមួយឆ្នាំកន្លងមកហើយ គឺនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១[43]។ ជាថ្មីម្តងទៀត ក.ស.ព ជាយុទ្ធសាស្ត្របានសម្រេចមិនប្តឹង ឬខកខានមិនប្តឹងសាទុក្ខ។

24. នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ រយៈពេលប្រាំខែបន្ទាប់ពីចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងជាថ្មីម្តងទៀតបានបដិសេធសំណើរបស់ ក.ស.ព សុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្តី ទោះបីជាមិនបានបញ្ជាក់ឲ្យបានច្បាស់ក៏ដោយ។ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់នូវការធានាឡើយទាក់ទិនទៅនឹងវិសាលភាពនៃការជំនុំជម្រះក្តី ដែលប្រការនេះបញ្ជាក់ច្បាស់ថា ប្រសិនបើអង្គជំនុំជម្រះសម្រេចធ្វើការកែប្រែវិសាលភាពនោះ អង្គជំនុំជម្រះនឹងធ្វើការកែប្រែដោយផ្អែកទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួន និងអនុលោមតាមឆន្ទានុសិទ្ធិរបស់ខ្លួនផ្ទាល់ក្នុងការរៀបចំសវនាការ (ឧទាហរណ៍ ជាជាង អនុលោមតាមសំណើរបស់ ក.ស.ព)[44]។ នេះគឺជាការប្រថុយប្រថានរបស់ ក.ស.ព នៅពេលដែល ក.ស.ព ជាយុទ្ធសាស្ត្របានជ្រើសយកជម្រើសមិនប្តឹងសាទុក្ខទៅនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមិនធ្វើការពិចារណាឡើងវិញ ទៅលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី (លុះត្រាតែ ក.ស.ព មិនបានបំពេញកិច្ច

[41] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124 កថាខណ្ឌ ២។

[42] សេចក្តីជូនដំណឹងអំពីសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញលើពាក្យ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124/1។

[43] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ថ្ងៃទី១៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/7។

[44] សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E172 ទំព័រ ៤។

ការដោយយកចិត្តទុកដាក់ ទើបមានមន្ទិលអំពីសមត្ថភាពរបស់ ក.ស.ព ដោយពិចារណាទៅចំនួនដ៏ច្រើននៃអ្នកជំនាញផ្នែកច្បាប់ដែលមានសមត្ថភាពរបស់ ក.ស.ព)។

25. យ៉ាងហោចណាស់ ក.ស.ព មានឱកាសពីរដង (បន្ទាប់ពីការចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងឱកាសម្តងទៀតបន្ទាប់ពីសេចក្តីសម្រេចលើការពិចារណាឡើងវិញ) ដើម្បីដាក់បណ្តឹងសាទុក្ខឱ្យបានទាន់ពេលវេលានៅក្នុងអំឡុងរយៈពេលកំណត់ដែលមានចែងនៅក្នុងវិធាន ១០៧(១)។ ក.ស.ព មិនបាន សូម្បីតែមានបំណងប្តឹងសាទុក្ខទៅនឹងអនុស្សរណៈក្រោយមកទៀតនោះឡើយ ដែលបញ្ជាក់ឱ្យឃើញច្បាស់ថា ការកែប្រែវិសាលភាពណាមួយនោះ នឹងមិនត្រូវបានធ្វើឡើងដោយអនុលោមតាមសំណើរបស់ ក.ស.ព ឡើយ ប៉ុន្តែដោយផ្អែកទៅលើគំនិតផ្តួចផ្តើមដោយផ្ទាល់របស់អង្គជំនុំជម្រះសាលាដំបូង និងតាមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។

26. បណ្តឹងសាទុក្ខគ្រាន់តែបញ្ជាក់ឡើងវិញនូវសារណាមុនៗរបស់ ក.ស.ព ដែលដាក់ជូនអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ។ នៅពេលនេះ ក.ស.ព ហាក់ដូចជាដាក់ក្តីសង្ឃឹមរបស់ខ្លួនទៅលើអង្គជំនុំជម្រះតុលាការកំពូលដើម្បីជួយដល់ ក.ស.ព ក្នុងការគេចវេះចេញពីសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។

27. ក.ស.ព កំពុងតែដាក់ការស្តីបន្ទោសទៅលើអង្គជំនុំជម្រះសាលាដំបូងដោយឥតអៀនខ្មាស់ ដើម្បីលាក់កំបាំងនូវការខកខានរបស់ខ្លួនផ្ទាល់ក្នុងការបំពេញកិច្ចការ ដោយយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់។ ប្រសិនបើ ក.ស.ព ពិតជាមាន "ក្តីព្រួយបារម្ភខ្លាំង"[45] ថា របៀបដែលអង្គជំនុំជម្រះបានសម្រេចបំបែកការជំនុំជម្រះក្តីនឹងធ្វើឱ្យប៉ះពាល់ដល់ "កេរដំណែល" (ដែលពុំមែនជាបញ្ហា ទាក់ទងនឹងរបៀបនៃការដោះស្រាយបញ្ហាផ្នែកច្បាប់នោះទេ លើកលែងតែសេចក្តីសម្រេចរបស់តុលាការ ជាសេចក្តីសម្រេចដែលផ្តោតជាសំខាន់ទៅលើលទ្ធផលដោយមានគោលបំណងជាក់លាក់ ពោលគឺលទ្ធផលពាក់ព័ន្ធនឹងបញ្ហាកេរដំណែល) របស់ អ.វ.ត.ក មែននោះ ក.ស.ព គួរតែបានប្តឹងសាទុក្ខចំពោះដីកាបំបែកកិច្ចដំណើរការនីតិវិធី ឬប្តឹងសាទុក្ខចំពោះការបដិសេធសំណើររបស់ខ្លួនសុំឱ្យមានការពិចារណាឡើងវិញនោះ។ ប្រហែលទំនងជា ក.ស.ព បានដឹង (និងទទួលយកទាំងមិនសប្បាយចិត្ត នាពេលនេះ) ថាពុំមានអត្ថិភាពនៃមូលដ្ឋានសម្រាប់បណ្តឹងសាទុក្ខភ្លាមៗឡើយ។

---

[45] បណ្តឹងសាទុក្ខ កថាខណ្ឌ ២។

28. ក.ស.ព មិនដែលពន្យល់ថាហេតុអ្វីបានជាខ្លួនមិនប្ដឹងសាទុក្ខនោះឡើយ។ ពុំមានសំអាងហេតុមួយណានៅក្នុងបណ្ដឹងសាទុក្ខនេះ ជាសំអាងហេតុថ្មីនោះឡើយ ៖ នៅក្នុងសំណើរបស់ខ្លួនសុំឱ្យមានការពិចារណាឡើងវិញ ដែលបានដាក់នៅក្នុងខែ តុលា ឆ្នាំ ២០១១ ក.ស.ព បានអះអាងថា សំណុំរឿង ០០២/០១ នឹងទំនងជាការជំនុំជម្រះក្ដីតែមួយប៉ុណ្ណោះ ដោយសារតែ *ក្នុងចំណោមប្រការផ្សេងទៀត* អាយុ និងសុខភាពរបស់ជនជាប់ចោទ និងការពិចារណាជាក់ស្ដែង និងបានអះអាងថា កេរដំណែលរបស់ អ.វ.ត.ក នឹងត្រូវចុះខ្សោយ ដោយសារបទចោទនានាដែលមិនតំណាងឱ្យអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់[46]។ សំណួរដែលសុំឱ្យមានការឆ្លើយតបនោះគឺថា ហេតុអ្វីបានជា ក.ស.ព មិនប្រើប្រាស់យន្តការប្ដឹងសាទុក្ខដែលខ្លួនអាចប្រើបាននោះ។ ការបំពេញការងារដោយយកចិត្តទុកដាក់តម្រូវឱ្យមានការចាត់វិធានការភ្លាមៗ មិនមែនគ្រាន់តែជាការធានាទៅលើលទ្ធផល មុនពេលមានការចាត់វិធានការឡើយ ពោលគឺ ការដាក់បណ្ដឹងសាទុក្ខ។

29. នៅពេលនេះ រយៈពេលកំណត់ក្នុងការដាក់បណ្ដឹងសាទុក្ខរបស់ ក.ស.ព បានផុតរលត់ហើយ។ ដោយពិចារណាទៅលើការប្រើប្រាស់យុត្តិសាស្ត្ររបស់តុលាការ ICTY ដ៏ច្រើនរបស់ ក.ស.ព នៅក្នុងការលើកឡើងនូវទឡ្ហីករណ៍របស់ខ្លួននោះ ក.ស.ព ពិតជាដឹងច្បាស់អំពីគោលការណ៍ណែនាំប្រុងប្រយ័ត្នរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី *Čelebići* ៖ "ជាគោលការណ៍ទូទៅ ភាគីមួយមិនគួរត្រូវបានអនុញ្ញាតមិនឱ្យប្ដឹងជំទាស់ទៅនឹងបញ្ហាមួយ ដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់ក្នុងអំឡុងដំណើរការជំនុំជម្រះក្ដី ហើយលើកឡើងនូវបញ្ហានោះតែនៅពេលដែលមានសំអាងហេតុដែលមានផលប៉ះពាល់ដល់ភាគីនោះឡើយ"[47]។ ក្នុងការការពារទល់នឹងការខាតបង់របស់ខ្លួន[48] ក.ស.ព បានប្រថុយ ៖ ជំនួសឱ្យការប្ដឹងសាទុក្ខ ក.ស.ព បានសន្មតដោយពុំមានភាពវៃឆ្លាតថា អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការ

---

[46] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង" ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E124/2 កថាខណ្ឌ ៣, ២៤-២៥, ២៩, ៣១-៣២, ៣៦។

[47] រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Delalić* និងអ្នកផ្សេងទៀត IT-96-21-A សាលដីកា ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៦៤០។

[48] ឃ្លា to *hedge your bets* (ការពារទល់នឹងការខាតបង់របស់ខ្លួន) ជាទូទៅមានន័យថា មិនធ្វើការប្ដេជ្ញាចិត្តក្នុងគោលជំហរ ឬសកម្មភាពណាមួយឡើយ ដើម្បីទុកចន្លោះក្នុងការដកខ្លួនចេញ។ នៅក្នុងករណីនេះ ដោយមិនធ្វើការប្ដឹងសាទុក្ខទៅនឹងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ឬសេចក្ដីសម្រេចក្រោយៗទៀត នៅពេលដែល ក.ស.ព គួរតែធ្វើនោះ ក.ស.ព កំពុងតែព្យាយាម ដោយក្ដីឆោតល្ងង់ដើម្បីទុកចន្លោះក្នុងការដកខ្លួនចេញ ដោយធ្វើការប្ដឹងសាទុក្ខទៅនឹងសេចក្ដីសម្រេចដែលត្រូវបានជំទាស់។

កែប្រែដោយខ្លួនឯង ហើយឥឡូវនេះ ដោយសារអង្គជំនុំជម្រះសាលាដំបូងមិនបានធ្វើការកែប្រែនោះ ក.ស.ព បែរជាលើកឡើងអំពីបញ្ហា "កេរដំណែល" និង "យុត្តិធម៌របស់ជនរងគ្រោះ" ជាមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់ខ្លួនទៅវិញ។

## ខ. បណ្តឹងសាទុក្ខមិនអាចទទួលយកបានជាបណ្តឹងសាទុក្ខភ្លាមៗឡើយ

### ១. បណ្តឹងសាទុក្ខភ្លាមៗត្រូវបានកំណត់យ៉ាងដាច់ខាតត្រឹមមូលដ្ឋានសម្រាប់បណ្តឹងសាទុក្ខដែលមានចែងនៅក្នុងវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង

30. ក.ស.ព ស្នើសុំដាក់ជាបណ្តឹងសាទុក្ខបន្ទាន់បង្ខំភ្លាមៗ ទាក់ទិនទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០១។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសារណាមុនៗរបស់ខ្លួន ក.ស.ព បានគាំទ្រវិសាលភាពដែលកំណត់ យ៉ាងដាច់ខាតសម្រាប់បណ្តឹងបន្ទាន់បង្ខំ[49] ដោយលើកទឡ្ហីករណ៍ម្តងហើយម្តងទៀតប្រឆាំងនឹងការពង្រីកណាមួយនៃវិធាន ១០៤[50]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្របសម្រួល។

[49] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឱ្យជនជាប់ចោទត្រូវមានវត្តមានដើម្បីស្តាប់ការចោទប្រកាន់ និងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារ E130/4/2 កថាខណ្ឌ ៥។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទាក់ទងដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E154/1/1/2 កថាខណ្ឌ ៩។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងការជូនដំណឹងអំពីបណ្តឹងសាទុក្ខចំនួនពីររបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធការពន្យារពេល និងចំនួនទំព័រកំណត់សម្រាប់ការដាក់អញ្ញត្រកម្មបឋម ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ឯកសារ E9/7/1/1/1/1 ទំព័រ ៥។

[50] ក.ស.ព ធ្លាប់បានអះអាងថា "ចេតនាច្បាស់លាស់ចំពោះវិសាលភាពដែលមានកម្រិតកំណត់ក្នុងវិធាន ១០៤ ត្រូវបានបញ្ជាក់... តាមរយៈការច្រានចោលនៅក្នុងកិច្ចប្រជុំពេញអង្គរបស់ចៅក្រមអ.វ.ត.ក ប្រព្រឹត្តឡើងក្នុងខែកុម្ភៈ ឆ្នាំ ២០១១ ចំពោះវិសោធនកម្មដើម្បីពង្រីកវិសាលភាពនៃវិធាននេះឱ្យរួមទាំងការដាក់បណ្តឹងភ្លាមៗទៅលើបញ្ហាជាច្រើនថែមទៀត" ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងការជូនដំណឹងអំពីបណ្តឹងសាទុក្ខចំនួនពីររបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធការពន្យារពេល និងចំនួនទំព័រកំណត់សម្រាប់ការដាក់អញ្ញត្រកម្មបឋម ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១ ឯកសារ E9/7/1/1/1/1 កថាខណ្ឌ ៥។ ថ្មីៗនេះ ទាក់ទិនទៅនឹងវិសោធនកម្មវិធាន ១០៤ ដែលបានស្នើឡើង ដោយមេធាវីការពារក្តីនៅក្នុងខែ កញ្ញា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញារងអន្តរជាតិ William Smith បានបញ្ជាក់ថា៖ "សហព្រះរាជអាជ្ញាសូមបញ្ជាក់អំពីជំហររបស់ខ្លួនថា សហព្រះរាជអាជ្ញាជំទាស់យ៉ាងដាច់ខាតចំពោះយន្តការបណ្តឹងសាទុក្ខបន្ទាន់បង្ខំ ជាពិសេស

អង្គជំនុំជម្រះ បានសម្រេចថា “ពុំមានសិទ្ធិជាទូទៅណាមួយក្នុងការប្ដឹងសាទុក្ខបន្ទាន់បន្ទំឡើយ”[51] ហើយថា យុត្តាធិការក្នុងការពិចារណាទៅលើបណ្ដឹងសាទុក្ខភ្លាមៗ *ត្រូវបានកំណត់យ៉ាងដាច់ខាត* ហើយសេចក្ដីសម្រេចនានាដែលស្ថិតនៅក្រៅវិសាលភាពនៃវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង អាចប្ដឹងសាទុក្ខបាន បន្ទាប់ពីចេញសាលក្រមចុងក្រោយសិន[52]។

31. បណ្ដឹងសាទុក្ខរបស់ ក.ស.ព ផ្អែកតែទៅលើបញ្ហានៃការរំលោភលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ។ ជាលទ្ធផល ក.ស.ព អះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានមិនបានអនុវត្តឱ្យ*បានច្រើន* មិនមែន*តិចតួច*ទេ នូវឆន្ទានុសិទ្ធិផ្នែកតុលាការរបស់ខ្លួន នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងពិតជាបានសម្រេចអនុវត្តឆន្ទានុសិទ្ធិនោះ។ ម្យ៉ាងវិញទៀត ពុំមានការប្រព្រឹត្តកំហុសឡើយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានសម្រេចមិនអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន

---

នៅពេលដែលលក្ខណវិនិច្ឆ័យក្នុងការទទួលយក មានលក្ខណៈទូលំទូលាយ ហើយយើងកំពុងតែធ្វើដំណើរឆ្ពោះទៅការបញ្ចប់ដំណើរការជំនុំជម្រះក្ដី។ សរុបមក សហព្រះរាជអាជ្ញា យល់ឃើញថា ថ្លៃចំណាយមានភាពធំជាងផលប្រយោជន៍ នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី”។ អ៊ីមែលពី William Smith ផ្ញើទៅ ស៊ា ម៉ៅ លេខាធិការដ្ឋាននៃគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង មានចំណងជើងថា៖ “យោង ៖ សំណើរបស់អង្គភាពគាំពារការពារក្ដី និង ក.ស.ព សុំឱ្យជម្រាបជូនសមាជិកគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង ស្ដីអំពីសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង” ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១២។

[51] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពី អញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (*Ne Bis in Idem*) និងការលើកលែងទោស និងការអនុគ្រោះទោស) ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E51/15/1/1 ទំព័រ ២។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ សាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង*របស់មន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E154/1/1/4 កថាខណ្ឌ ១៥។

[52] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង*របស់មន្ត្រីច្បាប់ជាន់ខ្ពស់ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E154/1/1/4 កថាខណ្ឌ ១២។ សេចក្ដីសម្រេចស្ដីពីសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E62/3/10/5/1។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ ឯកសារ E130/4/3។ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីអញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (*Ne Bis in Idem*) និងការលើកលែងទោស និងការអនុគ្រោះទោស) ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E51/15/1/1 ទំព័រ ២។

នោះ ប៉ុន្តែនៅពេលដែលអង្គជំនុំជម្រះបានសម្រេចអនុវត្តឆន្ទានុសិទ្ធិ នោះការប្រើឆន្ទានុសិទ្ធិ ឬអ្នករំលោភឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ នៅក្នុងករណីនេះ បង្កើតឱ្យមានយន្តការបណ្ដឹងសាទុក្ខបន្ទាន់បង្ខំតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង។

32. ផ្ទុយទៅនឹងការអះអាងរបស់ ក.ស.ព អង្គជំនុំជម្រះសាលាដំបូងពិចារណាថា បណ្ដឹងសាទុក្ខ ដែលពាក់ពាន់នឹងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន មិនអាចទទួលយកបានជាបណ្ដឹងបន្ទាន់បង្ខំភ្លាមៗឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "វិធាន *៨៩ស្ទួនពីរ* នៃវិធានផ្ទៃក្នុងដែលជាមូលដ្ឋាននៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិរៀបចំសវនាការ *ដោយភាគីពុំមានសិទ្ធិប្ដឹងសាទុក្ខឡើយ*"[53]។ វាបង្ហាញឱ្យឃើញថា ក.ស.ព បានយល់ស្រប ជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង ទៅលើការបកស្រាយរបស់អង្គជំនុំជម្រះអំពីវិធាន *៨៩ស្ទួនពីរ* ដោយសារតែពុំមានការដាក់បណ្ដឹងសាទុក្ខ ឬសូម្បីតែសំណើសុំឱ្យមានការបញ្ជាក់ឱ្យបានច្បាស់នោះ។

## ២. បណ្ដឹងសាទុក្ខនេះពុំអាចទទួលយកបាន អនុលោមតាមវិធាន ១០៤ (៤)

33. ក.ស.ព អះអាងថាបណ្ដឹងសាទុក្ខរបស់ខ្លួន មានលក្ខណៈអាចឱ្យទទួលយកបាន ដោយផ្អែកលើវិធាន ១០៤(៤)(ក)[54] ដែល "អនុញ្ញាតឱ្យធ្វើបណ្ដឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្ដីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី"[55]។ សេចក្ដីសម្រេចដែលត្រូវបានជំទាស់បានត្រឹមតែបដិសេធពុំ *បន្ថែម* ទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលត្រូវបានកំណត់រួចហើយ។ សេចក្ដីសម្រេចនេះពុំបញ្ចប់កិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន ឬកិច្ចដំណើរការនីតិវិធីនៅថ្ងៃខាងមុខ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះឡើយ[56]។ ផ្ទុយមកវិញ អង្គជំនុំជម្រះសាលាដំបូង

---

[53] សេចក្ដីជូនដំណឹងអំពីការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើ ដែលនៅសេសសល់មុនសវនាការ (ឯកសារ E20, E132, E134, E135, E124/8, E124/9, E124110, E136 និង E139) និងការណែនាំបន្ថែមទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E145 ទំព័រ ១ (សេចក្ដីបញ្ជាក់បន្ថែម)។

[54] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ១០។

[55] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីអញ្ញត្រកម្មរបស់លោក អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងការលើកលែងទោស និងការអនុគ្រោះទោស), ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E51/15/1/2 ទំព័រ ២។

[56] តាមពាក្យពេចន៍ផ្ទាល់របស់ ក.ស.ព៖ "អត្ថន័យធម្មតា និងការអះអាងរបស់វិធាន ១០៤[(៤)(ក)] គឺដើម្បីផ្ដល់ឧបាស្រ័យដល់បណ្ដឹងសាទុក្ខភ្លាមៗ ក្នុងករណីមានភាគីណាមួយចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសណាមួយដែលនាំឱ្យ *បញ្ចប់* កិច្ចដំណើរការនីតិវិធី មិនមែនក្នុងករណីដែលការចោទប្រកាន់អំពីកំហុសដែលនាំឱ្យ *បន្ត* កិច្ចដំណើរការនីតិវិធីឡើយ

បានគូសបញ្ជាក់យ៉ាងច្បាស់ថា៖ "*ពុំមានការចោទប្រកាន់ ឬបទចោទប្រកាន់ណាមួយក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានបញ្ឈប់ ដោយអានុភាពនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី*"[57] និងទើបបានប្រកាសកាលពីពេលថ្មីៗអំពីចេតនារបស់ខ្លួន "*ចាប់ផ្តើមសំណុំរឿង ០០២/០២ ភ្លាមៗ ក្រោយការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១ ...*"[58]។

34. ទឡ្ហីករណ៍របស់ ក.ស.ព ដែលថាបណ្តឹងសាទុក្ខនេះអាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ក) គឺផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ[59] ។ កាលៈទេសៈនៃសេចក្តីសម្រេចទាក់ទងនឹង អៀង ធីរិទ្ធ ខុសគ្នាច្បាស់ក្រឡែតពីសំណុំរឿងនាពេលបច្ចុប្បន្ន ដោយធ្វើឲ្យមានមន្ទិលអំពីសច្ចភាពរបស់ ក.ស.ព។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បណ្តឹងសាទុក្ខរបស់ ក.ស.ព អាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ក) *ដោយហេតុថា* អង្គជំនុំជម្រះសាលាដំបូងបានប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងអ្នកស្រី អៀង ធីរីទ្ធ និង៖

> ការផ្អាកដែលមិនមានភាពច្បាស់លាស់អំពីការបន្តដំណើរការនីតិវិធី គឺពិតជាមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីមិនឲ្យបន្តទៀត និងរារាំងដល់ការចេញសាលក្រមលើអង្គសេចក្តី។ ផលវិបាកនៃការអាក់ខានដែលបណ្តាលមកពីការផ្អាកកិច្ចដំណើរការនីតិវិធីនេះ មានកម្រិតធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថាសេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីនេះ ត្រូវតែជា

....", ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលដកលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារ E95/8/1/2 កថាខណ្ឌ ៤។

[57] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, ឯកសារ E124/7, កថាខណ្ឌ ៩ (មានបន្ថែមការបញ្ជាក់)។

[58] ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E218, កថាខណ្ឌ ១។

[59] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារ E138/1/7។

កម្មវត្ថុនៃបណ្ដឹងសាទុក្ខ។ ក្នុងកាលៈទេសៈពិសេសនេះ ការបកស្រាយសមហេតុផលតែមួយគត់នៃវិធាន១០៤(៤)(ក) នៃវិធានផ្ទៃក្នុង គឺថា "សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី" រួមបញ្ចូលផងដែរនូវសេចក្តីសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីនៅពេលដែលគ្មានក្តីសង្ឃឹមអំពីការបន្តនីតិវិធី[60]។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងអ្នកស្រី អៀង ធីរិទ្ធ គឺពិតជាសេចក្តីសម្រេចជាស្ថាពរដែលបានធានាថាសាលក្រមស្ថាពរក្នុងសំណុំរឿងនោះគឺពុំមានឡើយ លើកលែងតែអ្នកស្រី អៀង ធីរិទ្ធ ជាសះស្បើយដោយអច្ឆរិយហេតុណាមួយ។ ក.ស.ព កំពុងប្រើល្បិចផ្គិនផ្គែកដែលមានគ្រោះថ្នាក់ធ្ងន់ធ្ងរ។

35. សេចក្តីសម្រេចដែលត្រូវបានជំទាស់ ពុំផ្អាកកិច្ចដំណើរនីតិវិធីឡើយ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ពុំរារាំងមិនឲ្យមានសាលក្រមលើអង្គសេចក្តីបានឡើយ (ទោះជាពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ក្តី ឬការជំនុំជម្រះណាមួយនៅថ្ងៃមុខក្តី)។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ពុំមានផលរំខានឡើយ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់ពុំបញ្ចប់កិច្ចដំណើរការនីតិវិធីឡើយ។ សេចក្តីសម្រេចដែលត្រូវបានជំទាស់បានត្រឹមតែកំណត់វិសាលភាព នៃការជំនុំជម្រះនាពេលបច្ចុប្បន្នប៉ុណ្ណោះ ពោលគឺពុំបញ្ឈប់បទចោទ ឬការចោទប្រកាន់ណាមួយ ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ[61]។ សេចក្តីសម្រេចដែលត្រូវបានជំទាស់គឺជាសេចក្តីសម្រេចស្តីពីការរៀបចំសវនាការសុទ្ធសាធ ដែលស្ថិតក្នុងឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។

36. ទទ្បីករណ៍របស់ ក.ស.ព ដែលថាសេចក្តីសម្រេចដែលត្រូវបានជំទាស់ បានបញ្ចប់ដោយប្រសិទ្ធភាពនូវកិច្ចដំណើរការនីតិវិធី គឺផ្អែកទៅលើការប៉ាន់ស្មានថាការជំនុំជម្រះនៅថ្ងៃខាងមុខក្នុងសំណុំរឿង ០០២ គឺ "ស្ថិតនៅឆ្ងាយមើលមិនឃើញ"[62]។ មូលដ្ឋាននៃអំណះអំណាងរបស់ ក.ស.ព នេះគឺ "មេធាវីការពារក្តីរបស់ អៀង សារី នួន ជា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្លាប់បានបញ្ចេញ

---

[60] ដូចឯកសារយោងខាងលើ, កថាខណ្ឌ ១៥។

[61] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១១, ឯកសារ E124/7, កថាខណ្ឌ ៨ ។

[62] បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៥-១៩។

ទស្សនៈនេះរួចហើយ"[63] អាយុ និងសុខភាពរបស់ជនជាប់ចោទ[64] និងបញ្ហាជាច្រើនដែលមិនទាន់បានដោះស្រាយថាតើនៅពេលណា និងតាមរបៀបណាដែលសំណុំរឿងលេខ ០០២ ធំដូចនេះ អាចនឹងដំណើរការទៅមុខបាន"[65] គ្មានមូលដ្ឋានណាមួយក្នុងចំណោមមូលដ្ឋានទាំងនេះបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចណាមួយ ដែលបញ្ចប់ប្រកបដោយប្រសិទ្ធភាពនូវកិច្ចដំណើរការនីតិវិធី ដូចតាមការតម្រូវរបស់វិធាន ១០៤(៤)(ក) សម្រាប់ភាពអាចទទួលយកបានបណ្តឹងឧទ្ធរណ៍ឡើយ។

37. បើទោះបីជាមេធាវីការពារក្តីមានក្តីសោមនស្សដែល ក.ស.ព ចាត់ទុកអំណះអំណាងរបស់សហមេធាវីអន្តរជាតិ Michael G. Karnavas ពាក់ព័ន្ធនឹងលទ្ធភាពនៃការជំនុំជម្រះនៅថ្ងៃខាងមុខក្នុងសំណុំរឿង ០០២ ថាជាអំណះអំណាងដែលអាចជឿជាក់បានក៏ដោយ ក៏នេះពុំមែនជាមូលហេតុដើម្បីទទួលយកបណ្តឹងសាទុក្ខនេះដែរ[66]។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសម្តងហើយម្តងទៀតអំពីចេតនារបស់ខ្លួនក្នុងការធ្វើសវនាការនៅថ្ងៃខាងមុខក្នុងសំណុំរឿង ០០២ ហើយបើទោះបីជានាពេលបច្ចុប្បន្នតុលាការនេះមានវិបត្តិថវិកាក៏ដោយ ក៏ការជំនុំជម្រះជាច្រើនលើសំណុំរឿង ០០២ ដែលចំណាយពេលរហូតដល់ឆ្នាំ ២០១៨ (រួមទាំងបណ្តឹងសាទុក្ខ) ត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងថវិការបស់តុលាការផងដែរ[67]។

38. អាយុ និងសុខភាពរបស់ជនជាប់ចោទ និងបញ្ហាជាក់ស្តែងមួយចំនួនដែលត្រូវដោះស្រាយ ពាក់ព័ន្ធនឹងវិធី និងពេលវេលានៃការចាប់ផ្តើមសំណុំរឿង ០០២/០២ ពុំមានន័យថា កិច្ចដំណើរការនីតិវិធីទាំងនេះត្រូវបានបញ្ចប់ជាស្ថាពរឡើយ។ ក្នុងគ្រប់សំណុំរឿង លទ្ធភាពដែលថា ជនជាប់ចោទអាចពុំមានសម្បទាគ្រប់គ្រាន់ ឬអាចស្លាប់មុនពេលមានការកាត់សេចក្តី តែងតែមានជានិច្ច។ លទ្ធភាពនេះអាច

---

[63] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ១៥។

[64] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ១៦-១៧។

[65] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ១៨។

[66] ក្នុងឱកាសផ្សេងៗ ក.ស.ព ពុំមានភាពរារែកឡើយក្នុងការបង្ហាញថាការយល់ច្រឡំរបស់មេធាវីការពារក្តីអំពីអង្គហេតុនានា ពុំមានតម្លៃ៖ *សូមមើល ឧទាហរណ៍* ប្រតិចារឹក, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារ E1/143.1, ទំព័រ ២៩ (ភាសាអង់គ្លេស)។

[67] *សូមមើល* ឧបសម្ព័ន្ធ ក នៃគម្រោងថវិការបស់ អ.វ.ត.ក សម្រាប់ឆ្នាំ ២០១២-២០១៣, *ដែលមាននៅលើគេហទំព័រ* http://www.eccc.gov.kh/en/about-eccc/finances/annexes-eccc-budget-2012-2013។

មានកម្រិតខ្ពស់ខុសគ្នាពីសំណុំរឿងមួយទៅសំណុំរឿងមួយ ប៉ុន្តែការសន្និដ្ឋានថាភាពពុំមានសម្បទាគ្រប់គ្រាន់ ដែលអាចមាននៅថ្ងៃខាងមុខ របស់ជនជាប់ចោទ ឬការស្លាប់របស់ជនជាប់ចោទ បណ្តាលឲ្យកិច្ចដំណើរការនីតិវិធីនៅថ្ងៃមុខ ត្រូវបញ្ចប់ជាស្ថាពរនៅដំណាក់កាលនេះ ជាការសន្និដ្ឋានពុំត្រឹមត្រូវ និងជាការរាន់ច្រឡំ។ ក្នុងការជំនុំជម្រះនានាដែលត្រូវបានបំបែកទៅតាមបទចោទប្រកាន់នឹងមានបញ្ហាជាក់ស្តែងដើម្បីដោះស្រាយ។ បញ្ហាទាំងនេះគ្រាន់តែបង្ហាញអំពីការពន្យារពេលដែលអាចមានប៉ុណ្ណោះ ពុំមែនបញ្ចប់កិច្ចដំណើរការនីតិវិធីជាស្ថាពរឡើយ។

39. វិធាន១០៤(៤) ពុំអនុញ្ញាតឲ្យប្តឹងសាទុក្ខ ដោយផ្អែកលើការប៉ាន់ស្មានដូចដែល ក.ស.ព បានធ្វើឡើយ។ វិធាន ១០៤(៤) ចែងច្បាស់ថាបណ្តឹងសាទុក្ខដែលពុំមានចែងក្នុងវិធាន ១០៤(៤)(ក)-(ឃ) "អាចប្តឹងសាទុក្ខបាន*តែក្នុងករណី* ដែលបានធ្វើឡើងស្របពេលជាមួយបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើអង្គសេចក្តី"[68]។ អង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានបកស្រាយបញ្ញត្តិនេះយ៉ាងតឹងរ៉ឹង ដោយបានសម្រេចថា លោក អៀង សារី អាចត្រឹមតែប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាអង្គជំនុំជម្រះសាលាដំបូងមានអំណាចយុត្តាធិការដើម្បីធ្វើការជំនុំជម្រះគាត់ បើទោះបីជាគាត់មានការលើកលែងទោស និងការអនុគ្រោះទោសពីព្រះមហាក្សត្រ ហើយគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* គឺជាផ្នែកមួយនៃបណ្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចនេះក៏ដោយ[69]។ ការសម្រេចនេះត្រូវបានធ្វើឡើង ថ្វីបើមានបញ្ហាជាក់ស្តែងដែលថាគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* រារាំងមិនឲ្យមាន *ការកាត់សេចក្តីជាថ្មី* និងពុំមែនត្រឹមតែ *ការផ្តន្ទាទោសជាថ្មី* ទៅលើជនជាប់ចោទ ដោយផ្អែកលើទង្វើដដែលដូចកាលពីនៅក្នុងការជំនុំជម្រះមុនក៏ដោយ។ ហេតុដូច្នេះនៅពេលមានសាលក្រម នឹងពុំមានសំណងប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភណាមួយលើសិទ្ធិរបស់លោក អៀង សារី ក្នុងការពុំត្រូវបានទទួលការជំនុំជម្រះសាជាថ្មីឡើយ។

40. ស្រដៀងគ្នានេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា បណ្តឹងសាទុក្ខរបស់លោក អៀង សារី ជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ ក.ស.ព ដើម្បីដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺពុំ

---

[68] បន្ថែមការបញ្ជាក់។

[69] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស*), ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E51/15/1/1, ទំព័រ ២។

អាចឲ្យទទួលយកបានជាបណ្ដឹងសាទុក្ខភ្លាមៗ ដោយអនុលោមតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុងឡើយ[70]។ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើសេចក្ដីសម្រេចនេះ បើទោះបីជាសំណុំរឿង ០០២/០១ ពុំពិនិត្យអំពីភស្តុតាងនានាពាក់ព័ន្ធនឹងទំនាក់ទំនងរវាងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងជម្លោះប្រដាប់អាវុធក៏ដោយ។ ដូច្នេះ កិច្ចដំណើរការនីតិវិធីនឹងបានបញ្ចប់ដោយស្វ័យប្រវត្ត ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលបានពិចារណាអំពីអង្គសេចក្ដីនៃបណ្ដឹងសាទុក្ខ និងបដិសេធសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ ការខកខានពុំបានពិចារណាអំពីបញ្ហានេះ ធ្វើឲ្យប៉ះពាល់ដោយផ្ទាល់ទៅលើសច្ចភាពគតិយុត្តិ។

41. ផ្ទុយមកវិញ ក្នុងសំណុំរឿងនាពេលបច្ចុប្បន្ន ពុំមានមូលហេតុណាមួយដែលថាបណ្ដឹងសាទុក្ខបន្ទាប់ពីមានសេចក្ដីសម្រេច ពុំការពារផលប្រយោជន៍របស់ ក.ស.ព បានគ្រប់គ្រាន់នោះឡើយ។ ក.ស.ព អះអាងថាសិទ្ធិរបស់ខ្លួនអាចទទួលបានការគាំពារតែក្នុងដំណាក់កាលនេះប៉ុណ្ណោះ បើពុំដូច្នោះទេនឹង "ពុំមានសំណងប្រកបដោយប្រសិទ្ធភាពនៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹងកំហុសដែលត្រូវបានចោទប្រកាន់ ដោយហេតុថាពុំមានមូលដ្ឋានគតិយុត្តណាមួយ ដើម្បីដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានដកចេញទៅក្នុងបណ្ដឹងសាទុក្ខ"[71] ។ អំណះអំណាងនេះពុំត្រឹមត្រូវទេ។ វិធាន ១០៤(១) ចែងថាក្នុងករណីពាក់ព័ន្ធនឹងកំហុសលើបញ្ហាអង្គច្បាប់ដែលធ្វើមោឃភាពសាលក្រម ឬសេចក្ដីសម្រេច ឬកំហុសអង្គហេតុដែលបានបណ្ដាលឲ្យមានការសម្រេចដោយគ្មានយុត្តិធម៌ "អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯងអាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មីដើម្បីធ្វើការសម្រេចលើបញ្ហានេះ"។

### ៣. វិធាន ២១ ពុំគាំទ្រការទទួលយកបណ្ដឹងសាទុក្ខឡើយ

42. ក.ស.ព អះអាងថាវិធាន ២១ គាំទ្រលទ្ធភាពនៃការទទួលយកបណ្ដឹងសាទុក្ខ ដោយហេតុថាវិធាន ២១ "បង្គាប់ថាវិធានផ្ទៃក្នុង "ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកប

[70] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E95/8/1/4។

[71] បណ្ដឹងសាទុក្ខ, កថាខណ្ឌ ១៣។

ដោយតម្លាភាព"[72]។ ក.ស.ព អះអាងថាការអនុញ្ញាតឲ្យមានបណ្តឹងសាទុក្ខភ្លាមៗ នឹងពុំមានផល ប៉ះពាល់អវិជ្ជមានណាមួយមកលើភាគីឡើយ ប៉ុន្តែអាចការពារដល់សិទ្ធិរបស់ជនរងគ្រោះ និងលើក កម្ពស់តម្លាភាព "ពាក់ព័ន្ធនឹងសុពលភាព និងសំអាងហេតុ ការបំបែកកិច្ចដំណើរការនីតិវិធី និងថាតើ មានការរំពឹងទុកប្រកបដោយភាពប្រាកដនិយមដែលថា តុលាការនេះនឹងវិនិច្ឆ័យលើការចោទប្រកាន់នានា ដែលពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្ម ដែលមិនបានដាក់បញ្ចូលនៅថ្ងៃខាងមុខដែលអាចប្រមើលឃើញ"[73]។

43. សុពលភាព និងហេតុផលនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី គឺពុំចាំបាច់មានតម្លាភាពជាង នេះទៀតឡើយ។ ក.ស.ព បានទទួលស្គាល់សុពលភាពនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ រួចរាល់ហើយ[74] ដែលត្រូវបានធ្វើដោយអនុលោមតាមវិធាន ៨៩ *ស្ទួនពីរ*។ អង្គជំនុំជម្រះសាលាដំបូង បានពន្យល់ម្តងហើយម្តងទៀត អំពីមូលហេតុនៃការសម្រេចបំបែកការជំនុំជម្រះ ដូចដែលខ្លួនបានធ្វើ និងបានបង្កើតតារាងពេលវេលាសម្រាប់ការធ្វើសវនាការជំនុំជម្រះ នៅថ្ងៃខាងមុខនៅក្នុងពេលអនាគត ដែលអាចប្រមើលឃើញ[75]។ ជាងនេះទៀត ពុំមានភាពចាំបាច់ដែលត្រូវអនុវត្តវិធាន ២១ ដើម្បីការពារ សិទ្ធិរបស់ជនរងគ្រោះឡើយ។ សិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារគ្រប់គ្រាន់តាមរយៈការផ្តល់សិទ្ធិ ប្តឹងសាទុក្ខចំពោះសេចក្តីសម្រេច ដែលរងការជំទាស់នៅដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធី ប្រសិនបើចាំបាច់ ដោយពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមានបំណងស្តាប់ភស្តុតាង ទាក់ ទងនឹងទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានស្នើសុំនៅក្នុងការជំនុំជម្រះលើសំណុំរឿង ០០២ នៅពេលក្រោយ ទៀត។

44. ដូចដែល ក.ស.ព ធ្លាប់បានអះអាង វិធាន ២១ គឺជា "បញ្ញត្តិទូទៅមួយដែលដើរតួនាទីសំខាន់ជាវិធាន សម្រាប់ការបកស្រាយ" ដែល "មិនអាចលប់លើខ្លឹមសារដ៏ច្បាស់លាស់ និងគ្មានភាពស្រពិចស្រពិល

---

[72] *ដូចឯកសារយោងខាងលើ*, កថាខណ្ឌ ១៩។

[73] *ដូចឯកសារយោងខាងលើ*។

[74] ក.ស.ព បានគូសបញ្ជាក់ថាខ្លួន *"សូមគាំទ្រទាំងស្រុងនូវការចាំបាច់ក្នុងការបំបែកសំណុំរឿង០០២ និងគោរពតាមសមត្ថកិច្ច របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ និងបើ មិនដូច្នោះទេ គឺដើម្បីធ្វើការគ្រប់គ្រងលើការបែងចែកពេលវេលា និងធនធាននៅពេលសវនាការ"*។ សេចក្តីជូនដំណឹងអំពីសំណើ របស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញលើពាក្យ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង", ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារ E124/1, កថាខណ្ឌ ៤ ។

[75] *សូមមើល* ផ្នែកស្តីពីសាវតារ, *ដូចជើងទំព័រខាងលើ*។

នៃវិធាន ១០៤(៤)"[76]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា "ខុសគ្នាឆ្ងាយពីការធានាជាស្វ័យប្រវត្ត... ការបកស្រាយវិធានផ្ទៃក្នុងក្នុងគ្រប់កាលៈទេសៈ [វិធាន ២១] "ត្រូវតែអានក្នុងន័យថា ការបកស្រាយវិធានផ្ទៃក្នុង មិនត្រូវឲ្យមានការរំលោភលើប្រយោជន៍ណាមួយរបស់ជនជាប់ចោទដែលកើតចេញពីសិទ្ធិសារវ័ន្តដែលត្រូវបានធានានៅក្នុងលក្ខន្តិកៈ និងលិខិតុបករណ៍អន្តរជាតិនានាជាធរមាន"[77]។

45. សិទ្ធិរបស់លោក អៀង សារី នឹងត្រូវបានរំលោភ ប្រសិនបើបណ្តឹងសាទុក្ខនេះត្រូវបានសម្រេចថាអាចទទួលយកបាន។ ការទទួលយកបណ្តឹងសាទុក្ខនេះនឹងបង្ហាញឲ្យឃើញអំពីការយកចិត្តទុកដាក់មិនស្មើគ្នារវាង ក.ស.ព និងមេធាវីការពារក្តី ដោយហេតុថា បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីដែលត្រូវបានធ្វើដោយអនុលោមតាមវិធាន ១០៤(៤)(ក) ត្រូវបានសម្រេចថាពុំអាចទទួលយកបាន បន្ទាប់ពីមានការបកស្រាយវិធាន ១០៤(៤)(ក) ក្នុងន័យចង្អៀត បើទោះបីជាមេធាវីការពារក្តីនឹងពុំទទួលសំណងគ្រប់គ្រាន់ ប្រសិនបើបណ្តឹងសាទុក្ខនេះត្រូវបានធ្វើសវនាការ បន្ទាប់ពីមានការចេញសាលក្រមរួចហើយ[78]។ ជាងនេះទៅទៀត ការដាក់បន្ថែមទីតាំងឧក្រិដ្ឋកម្មក្នុងសំណុំរឿង ០០២/០១ មានភាពយឺតយ៉ាវ ហើយប្រសិនបើទីតាំងឧក្រិដ្ឋកម្មទាំងនេះត្រូវបានដាក់បន្ថែម មេធាវីការពារក្តីនឹងត្រូវការការជូនដំណឹង និងពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំ នៅមុនពេលនៃការស្តាប់ភស្តុតាងនានា ស្តីពីទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំងនេះ។ នេះជាកត្តាមួយដែលអង្គជំនុំជម្រះសាលាដំបូងលើកយកមក

---

[76] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់គាត់ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទាក់ទងដោយចំហរ និងដោយតម្លាភាពជាមួយភាគីទាំងអស់, ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២, E154/1/1/2, កថាខណ្ឌ ៩។

[77] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយ *តែភាគីម្ខាង* របស់មន្ត្រីច្បាប់ជាន់ខ្ពស់, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២, ឯកសារ E154/1/1/4, កថាខណ្ឌ ១៤។

[78] *សូមមើល* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (*គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស*), ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E51/15/1/1, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២, ឯកសារ E95/8/1/4។

ពិចារណាជាពិសេស ក្នុងសេចក្តីសម្រេចមិនពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដូចតាមសំណើ ក.ស.ព[79]។

## III សន្និដ្ឋាន និងការស្នើសុំ

46. ដោយសារការសន្មតខុសទំនង នាពេលបច្ចុប្បន្ន ក.ស.ព កំពុងតែរកមធ្យោបាយដោះស្រាយយករួចខ្លួនវិញ។ ដោយហេតុថា ការសម្រេចមិនដាក់បណ្តឹងសាទុក្ខពីដំបូងរបស់ ក.ស.ព បានធ្វើឲ្យខ្លួនទទួលផលមិនជាទីគាប់ចិត្ត ទើបតាមរយៈបណ្តឹងសាទុក្ខយឺតយ៉ាវ និងដែលពុំអាចទទួលយកបានរបស់ខ្លួន ក.ស.ព សូមអង្វរឲ្យអង្គជំនុំជម្រះតុលាការកំពូលជួយសង្គ្រោះខ្លួន។

47. ដើម្បីបិទបាំងការខ្វះការយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវរបស់ខ្លួន និងការពិតដែលថាបណ្តឹងសាទុក្ខរបស់ខ្លួនពុំអាចទទួលយកបានយ៉ាងច្បាស់ក្រឡែតនៅដំណាក់កាលនេះ ក.ស.ព ប្រើប្រាស់ឧបាយកលដាក់សម្ពាធ។ ក.ស.ព កំពុងប្រើប្រាស់ឧបាយកលនេះ តាមរយៈការដាក់សម្ពាធនយោបាយទៅលើអង្គជំនុំជម្រះតុលាការកំពូល ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើអ្វីមួយដែលអង្គជំនុំជម្រះសាលាដំបូងនឹងពុំធ្វើ ដោយនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ក.ស.ព បានសម្តែង "ការព្រួយបារម្ភខ្លាំង" ដែលថាសេចក្តីសម្រេចដែលត្រូវបានជំទាស់ធ្វើឲ្យកេរដំណែលរបស់ អ.វ.ត.ក បរាជ័យ[80] និងដោយយកបញ្ហារបស់ខ្លួនទៅផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មានទៀតផង[81]។

---

[79] អង្គជំនុំជម្រះសាលាដំបូងបានស្នើមកមេធាវីការពារក្តីនៅឯកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ នូវចំណុចដូចខាងក្រោម៖ "សេចក្តីសន្និដ្ឋានផ្ទាល់មាត់ដោយមានសំអាងហេតុពាក់ព័ន្ធនឹងពេលវេលាដែលក្រុមមេធាវីការពារក្តីត្រូវការដើម្បីរៀបចំការការពារក្តីឲ្យបានសមស្របពាក់ព័ន្ធនឹងផ្នែកនានាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធសម្ងាត់ (និងកាលបរិច្ឆេទឆាប់បំផុតដែលក្រុមមេធាវីការពារក្តីពិចារណាឃើញថា បុគ្គលទាំងឡាយដែលមានឈ្មោះក្នុងឧបសម្ព័ន្ធនេះអាចត្រូវបានកោះហៅមកចំពោះមុខអង្គជំនុំជម្រះ)", ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E218, កថាខណ្ឌ១៥(ខ)។ បញ្ហានេះត្រូវបានក្រុមមេធាវីការពារក្តីនីមួយៗពិភាក្សានៅឯកិច្ចប្រជុំរៀបចំសវនាការ, ប្រតិចារឹក, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២, ឯកសារ E1/114.1, ទំព័រ ១០៥-១៨។

[80] បណ្តឹងសាទុក្ខ,កថាខណ្ឌ ២។

[81] លោក Cayley ធ្លាប់បានប្រើប្រាស់ឧបាយកលមួយស្រដៀងនេះពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ដោយបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ក្នុងបំណងដាក់ឥទ្ធិពលលើកិច្ចស៊ើបសួរតាមផ្លូវតុលាការនៅក្នុងសំណុំរឿងទាំងនោះ។ *សូមមើល* សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ *ដែលមាននៅលើគេហទំព័រ* http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-case-file-003; សេចក្តីថ្លែងការណ៍

48. អត្ថបទសារព័ត៌មាន Cambodia Daily កាលពីពេលថ្មីៗ បានរាយការណ៍ថា សហព្រះរាជអាជ្ញាអន្តរជាតិ Andrew Cayley បានសម្តែងទឹកចិត្តសាទរយ៉ាងជ្រាលជ្រៅ និងបានគូសបញ្ជាក់ថាគាត់ "មានជំនឿមុតមាំ" ថាអង្គជំនុំជម្រះតុលាការកំពូលនឹងធ្វើសវនាការលើបណ្តឹងសាទុក្ខ ហើយគាត់រំពឹងថាអង្គជំនុំជម្រះតុលាការកំពូលនឹងសម្រេចលើបណ្តឹងសាទុក្ខនេះ ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខ[82]។ លោក Cayley បានគូសបញ្ជាក់ថា "ឧក្រិដ្ឋកម្មសំខាន់បំផុតសម្រាប់ប្រជាជនកម្ពុជាគឺការកាប់សម្លាប់ប្រជាជន។ ខ្ញុំពុំមែនត្រៀមខ្លួនដើម្បីមើលឃើញកេរដំណែលតុលាការនេះពាក់ព័ន្ធនឹងអ្នកទទួលខុសត្រូវខ្ពស់បំផុត កំហិតត្រឹមតែការជម្លៀសប្រជាជនដោយបង្ខំឡើយ"[83]។ ដូចអង្គជំនុំជម្រះទាំងអស់នៅ អ.វ.ត.ក ដែរ អង្គជំនុំជម្រះតុលាការកំពូលមិនត្រូវយកចិត្តទុកដាក់ចំពោះការប្រើប្រាស់វេទិការបស់ ក.ស.ព (តាមរយៈសហព្រះរាជអាជ្ញាអន្តរជាតិ) ជាមធ្យោបាយដាក់សម្ពាធជាសាធារណៈ ដើម្បីនាំមកនូវលទ្ធផលដែលគ្មានមូលដ្ឋានគតិយុត្តិឡើយ។ គុណភាពនៃសេចក្តីសម្រេចរបស់តុលាការនេះ ទើបជាអ្នកកំណត់កេរដំណែលនៃតុលាការនេះ ដែលជាសេចក្តីសម្រេចដែលត្រូវតែធ្វើដោយអនុលោមតាមច្បាប់ និងពុំផ្អែកលើមនោសញ្ចេតនា ឬការរើសអើង និងសម្ពាធនយោបាយជាសាធារណៈ ដូចករណីនេះជាដើម។

49. បណ្តឹងសាទុក្ខរបស់ ក.ស.ព ត្រូវបានរារាំងដោយពេលវេលា និងពុំអាច ទទួលយកបាន អនុលោមតាមវិធាន១០៤(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែបដិសេធបណ្តឹងសាទុក្ខនេះ។ ក្នុង

---

របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៤ *ដែលមាននៅលើគេហទំព័រ* http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-case-file-004។

[82] Lauren Crothers, *សហព្រះរាជអាជ្ញាប្តឹងសាទុក្ខជំទាស់នឹងការដកទីតាំងឧក្រិដ្ឋកម្មចំនួន ២ ចេញពីក្នុងសំណុំរឿង ០០២,* សារព័ត៌មាន Cambodia Daily, ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១២, ទំព័រ ២០។

[83] *ដូចឯកសារយោងខាងលើ។ សូមមើលផងដែរ* Wallace& Kuch Naren, *"សវនាការតូចៗ" ជាកំបិតមុខពីរសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម,* សារព័ត៌មាន Cambodia Daily, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១២, ទំព័រ ១៖ "សហព្រះរាជអាជ្ញាឯកភាព [ថាទំនងជាពុំមានឡើយសវនាការជំនុំជម្រះនៅថ្ងៃខាងមុខ] និងបានគូសបញ្ជាក់ដោយចំហរចំនួនជាច្រើនលើកថា ការជំនុំជម្រះដំណាក់កាលទីពីរនឹងពុំមានឡើយ។ កាលពីខែតុលា សហព្រះរាជអាជ្ញាបានស្នើសុំឲ្យចៅក្រមពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដើម្បីដាក់បញ្ចូលការដ្ឋាន សហករណ៍ និងការកាប់សម្លាប់មួយចំនួនបន្ថែមទៀត ទៅក្នុងការជំនុំជម្រះតូចដំណាក់កាលទីមួយនេះ។ បន្ទាប់ពីសំណើរបស់សហព្រះរាជអាជ្ញាត្រូវបានបដិសេធ សហព្រះរាជអាជ្ញាបានស្នើសុំដាក់បញ្ចូលត្រឹមតែទីកន្លែងប្រហារសម្លាប់មនុស្ស និងគុកមួយចំនួនដែលទាក់ទងនឹងការជម្លៀសប្រជាជនប៉ុណ្ណោះ។ ជាថ្មីម្តងទៀត សំណើរបស់ពួកគាត់ត្រូវបានបដិសេធ"។

ការច្រានចោលបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងដាក់ការប្រុងប្រយ័ត្នទៅលើ ក.ស.ព ដែលអាចជាការបង្កើនការប្រុងប្រយ័ត្នដើម្បីឲ្យ ក.ស.ព នៅថ្ងៃមុខ អនុវត្តនីតិវិធីដោយមានការយកចិត្តទុកដាក់តាមការតម្រូវ និងតាមការរំពឹងទុករបស់ភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២។ ក.ស.ព ពុំមានបុព្វសិទ្ធិលើសលប់ឡើយ។

**អាស្រ័យហេតុនេះ** តាមសំអាងហេតុដូចដែលបញ្ជាក់ក្នុងចម្លើយតបនេះ មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលសម្រេចថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា**ពុំអាចទទួលយកបាន**។

សូមអង្គជំនុំជម្រះតុលាការកំពូលទទួលនូវសេចក្តីគោរពអំពីយើងខ្ញុំ។

________________ ________________

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២